# ប្រកាស
# ស្តីពី
# វិសោធនកម្មលើប្រកាសលេខ ធ ៧-០០-៥១ ប្រក
# ស្តីពី
# ចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់
# និងបំណុលសង្ស័យរួមទាំងការប្រាក់ដែលបានព្យួរ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/ ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/ ០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- បានឃើញប្រកាសលេខ ធ ៧-០០-៥១ ប្រក ស្តីពីចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យរួមទាំងការប្រាក់ដែលបានព្យួរ
- យោងតាមស្មារតីនៃការប្រជុំក្រុមការងារផ្នែកសេវាកម្មធនាគារនិងហិរញ្ញវត្ថុជាមួយវិស័យឯកជន នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០២

## សំរេច

**ប្រការ ១ :**

ធ្វើវិសោធនកម្មប្រការ៤ នៃប្រកាសលេខ ធ៧-០០-៥១ ប្រក ស្តីពីចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់និងបំណុលសង្ស័យរួមទាំងការប្រាក់ដែលបានព្យួរ ដែលមាន

ខ្លឹមសារដូចខាងក្រោម :

កំរិតអប្បបរមាចាំបាច់នៃការធ្វើសំវិធានធនដាក់លាក់ ដោយផ្អែកលើចំណាត់ថ្នាក់ដែលពាក់ព័ន្ធត្រូវមានដូចខាងក្រោម :

| | | |
|---|---|---|
| បំណុលក្រោមស្តង់ដា | : | ១០% ដោយមិនគិតដល់តំលៃទ្រព្យសម្បត្តិដែលបានដាក់ជាវត្ថុបញ្ចាំលើកលែងតែសាច់ប្រាក់ |
| បំណុលសង្ស័យ | : | ៣០% ដោយមិនគិតដល់តំលៃទ្រព្យសម្បត្តិដែលបានដាក់ជាវត្ថុបញ្ចាំលើកលែងតែសាច់ប្រាក់ |
| បំណុលបាត់បង់ | : | ១០០% បើធនាគារអាចបង្ហាញភស្តុតាងជាក់ស្តែងតាមករណីនីមួយៗនូវទ្រព្យសម្បត្តិដែលបានដាក់ជាវត្ថុបញ្ចាំ និងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ។ ចំនួនឥណទានដែលពុំមានសំភារៈធានាត្រូវធ្វើសំវិធានធន ។ |

**ប្រការ ២ :**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និង ក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ៣ :**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០២

**ទេសាភិបាល**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពតិមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"